វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១១ លេខ ០២

## បង្កើតបរិយាកាសអំណោយផលសម្រាប់វិនិយោគផ្នែកអាជីវកម្ម និងពាណិជ្ជកម្ម៖ ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ

"កម្ពុជា ជាកន្លែងងាយធ្វើអាជីវកម្ម .... បញ្ហាប្រឈមនៅតែមាន តែនិន្នាការអាចឃើញច្បាស់៖ កម្ពុជាកំពុងធ្វើដំណើរក្នុងទិសដៅត្រឹមត្រូវ។"

*លោក Stephen Higgins*

*អគ្គនាយកនៃធនាគារ ANZ Royal*

### ក្របខ័ណ្ឌសម្រាប់កំណើនប្រកបដោយនិរន្តរភាព[១]

ស្របពេលសេដ្ឋកិច្ចបានងើបឡើងវិញយ៉ាងល្អនេះ កម្ពុជាកំពុងប្រឹងប្រែងអនុវត្តឲ្យបានប្រសើរបំផុត នូវមាគ៌ាកំណើនរយៈពេលមធ្យម និងវែង។ បញ្ហាស្នូល គឺការប្រែក្លាយសន្ទុះដំបូងនៃការងើបឡើងវិញនេះ ឲ្យទៅជាការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយនិរន្តរភាព និងសមធម៌ ហើយទម្រង់នៃពាណិជ្ជកម្ម និងវិនិយោគរបស់កម្ពុជានាពេលអនាគត គឺជាកត្តាមួយដ៏សំខាន់សម្រាប់ការវិវត្តឡើងនេះ។

គោលនយោបាយអន្តរាគមន៍ខាងពាណិជ្ជកម្ម និងការវិនិយោគ ចែកចេញជាពីរផ្នែកធំៗ គឺ ១) ការអភិវឌ្ឍផ្នែករូបវន្ត ដូចជា បណ្តាញដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផ្សេងទៀត និង ២) ការបង្កើតគោលនយោបាយ បទបញ្ញត្តិ និងបរិយាកាសស្ថាប័នអំណោយផល សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគ។

ស្របពេលដែលការអភិវឌ្ឍផ្នែករូបវន្ត និងឧត្តមភាពប្រៀបធៀបផ្សេងទៀត កំពុងជំរុញកំណើនពាណិជ្ជកម្ម និងវិនិយោគ អ្នករៀបចំគោលនយោបាយរបស់កម្ពុជា ក៏មើលឃើញឱកាសល្អ ដើម្បីទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនបំផុតពីកំណើននេះ តាមរយៈការកែលំអក្រមខ័ណ្ឌស្ថាប័ន និងគោលនយោបាយឲ្យបានសមស្រប។

ក្របខ័ណ្ឌគោលនយោបាយ និងបទបញ្ញត្តិសមស្រប អនុវត្តដោយស្ថាប័នមានតម្លាភាពល្អ គឺជាធាតុផ្សំដ៏សំខាន់មួយ ដើម្បីជួយសម្រួលដល់កំណើនពាណិជ្ជកម្ម និងវិនិយោគ ហើយក៏ជាឧបករណ៍មួយសម្រាប់កំណត់ពីបែបបទ ដែលពាណិជ្ជកម្ម និងវិនិយោគ វាកំណត់នូវទ្រង់ទ្រាយប្រទេសកម្ពុជានាពេលអនាគត។ ក្របខ័ណ្ឌគោលនយោបាយ និងបទបញ្ញត្តិសមស្រប ក៏អាចរួមចំណែកបង្កើតជា លទ្ធផលដែលមាននិរន្តរភាព និងសមធម៌ផងដែរ។

### ការសម្របសម្រួលគោលនយោបាយពាណិជ្ជកម្ម

ពាណិជ្ជកម្ម ជាកម្លាំងជំរុញមួយក្នុងដំណើរការផ្លាស់ប្តូរសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើត និងអនុវត្តក្របខ័ណ្ឌគោលនយោបាយ ដែលបានប្រែក្លាយកម្ពុជាពីប្រទេសមានសេដ្ឋកិច្ចស្ទើរតែបិទជិត ទៅជាប្រទេសមានសេដ្ឋកិច្ចបើកចំហបំផុតក្នុងតំបន់ ក្នុងរយៈពេល ២ទសវត្សរ៍កន្លងមកនេះ។ ដូចមានបង្ហាញក្នុងរូបភាព ១ និន្នាការនេះរំពឹងថានឹងបន្តទៀត ហើយធនាគារពិភពលោកបានប៉ាន់ស្មានថា ការនាំចេញ និងនាំចូល នឹងកើនឡើងជាបន្តបន្ទាប់ក្នុងពីរបីឆ្នាំខាងមុខនេះ។

ការចូលជាសមាជិក សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (១៩៩៩) និងអង្គការពាណិជ្ជកម្មពិភពលោក (២០០៤) ព្រមទាំងកំណើនកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ ដែលជាផ្នែកមួយនៃក្របខ័ណ្ឌមហាអនុតំបន់មេគង្គ (GMS) មានសារៈសំខាន់ណាស់ក្នុងការបើកទីផ្សារសម្រាប់ទំនិញ និងសេវាកម្មរបស់កម្ពុជា។ ដោយឡែកការអនុវត្តរបៀបវារៈទាក់ទងនឹងអង្គការពាណិជ្ជកម្មពិភពលោក បានរួមចំណែកច្រើនណាស់

១ អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១១ បកស្រាយដោយលោក Stephen Higgins អគ្គនាយកនៃធនាគារ ANZ Royal លោក Stephane Guimbert សេដ្ឋវិទូជាន់ខ្ពស់នៃធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា និង ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១១: ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

រូបភាព ១៖ ទម្រង់ពាណិជ្ជកម្មរបស់កម្ពុជា




ប្រភព៖ ធនាគារពិភពលោក (ការប៉ាន់ស្មានពីឆ្នាំ 2010-2012)

ក្នុងការបង្កើតបរិយាកាសងាយស្រួល សម្រាប់ពាណិជ្ជកម្ម។ ជាលទ្ធផលនៃការចូលជាសមាជិកនេះ គេបានកំណត់ឃើញក្នុងឆ្នាំ២០០៤ ថា មានប្រមាណ ៧០កំណែទម្រង់ផ្នែកច្បាប់ដែលត្រូវធ្វើឡើង ហើយក្នុងនេះមានជិតដល់ ២ ភាគ ៣ ដែលបានអនុវត្តចប់សព្វគ្រប់ហើយ។

ដោយក្រឡេកមើលទៅអនាគត រដ្ឋាភិបាលបានផ្តោតលើការធ្វើពិពិធកម្មមុខផលិតផលនាំចេញរបស់ខ្លួន។ ការផ្លាស់ប្តូរពីទីផ្សារនាំចេញបែបប្រពៃណី ដូចជា ផលិតផលកាត់ដេរ ទៅកាន់ផ្នែកផ្សេងៗទៀត ដូចជា កសិកម្ម ជាដើម អាចជួយធានានូវកំណើនរយៈពេលវែង ដែលមានឥទ្ធិពលខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ។ គោលនយោបាយពាណិជ្ជកម្ម មានតួនាទីធំណាស់ក្នុងការជំរុញកម្ពុជាឲ្យឈានទៅរកផលិតផល និងសេវាកម្មសម្រាប់នាំចេញថ្មីៗ ទីផ្សារនៅតាមភូមិសាស្ត្រថ្មីៗ និងឲ្យឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម។

យុទ្ធសាស្ត្រពិពិធកម្មរបស់រដ្ឋាភិបាល ត្រូវជួយសម្របសម្រួលធនធានសម្រាប់ការរៀបចំគោលនយោបាយ ដើម្បីឲ្យគោលនយោបាយនោះមានឥទ្ធិពលខ្លាំងបំផុត។ ក្នុងនេះត្រូវកេណ្ឌប្រមូលធនធានហិរញ្ញវត្ថុ និងបច្ចេកទេសរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីលុបបំបាត់ឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍវិស័យនាំចេញថ្មីៗ។

អភិក្រមគ្របដណ្តប់ទូទាំងវិស័យពាណិជ្ជកម្ម (SWAp) គឺជាក្របខ័ណ្ឌដ៏សំខាន់មួយ សម្រាប់បញ្ជ្រាបគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋាភិបាល និងព្យាយាមកេណ្ឌប្រមូលធនធានមកបម្រើគោលដៅរួម។ បច្ចុប្បន្ន គម្រោងទាំងឡាយក្រោមក្របខ័ណ្ឌនេះ (ផ្តល់មូលនិធិដោយធនាគារពិភពលោក AusAid, Danida, JICA និង អង្គការជាច្រើនទៀត) គេបានរៀបចំជាមូលដ្ឋានគ្រឹះ ៣ សម្រាប់ជំរុញពិពិធកម្មផលិតផលនាំចេញ គឺមានកំណែទម្រង់ច្បាប់ និងគោលនយោបាយ ការអភិវឌ្ឍវិស័យនាំចេញ និងការកសាងសមត្ថភាពស្ថាប័ន។

កន្លងមក ការងារសម្របសម្រួលរវាងដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល បានបោះជំហានទៅមុខជាច្រើនហើយ ប៉ុន្តែនៅមានបញ្ហាប្រឈមធំៗមួយចំនួនទៀតដែលត្រូវដោះស្រាយ ក្នុងនេះបញ្ហាធំជាងគេ គឺភាពលំបាកក្នុងការសម្របសម្រួលរបៀបវារៈនានាដែលនៅពីក្រោយជំនួយអភិវឌ្ឍន៍។ ចំណាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍន៍ ជារឿយៗវាប្រទាំងប្រទើសគ្នាជាមួយតម្រូវការឲ្យមានអន្តរាគមន៍សម្របសម្រួល។ នាបច្ចុប្បន្ន ការកេណ្ឌប្រមូល និងលៃលែកធនធានឲ្យបានប្រសើរបំផុត កំពុងជួបឧបសគ្គរាំងស្ទះដោយសារភាពទន់ខ្សោយខាងស្ថាប័ន។

## គោលនយោបាយពាណិជ្ជកម្មដ៏ខ្លាំងក្លា និងផ្តោតចំគោលដៅ

គោលនយោបាយ ចាំបាច់ត្រូវតែឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចដែលផ្លាស់ប្តូរចុះឡើងក្នុងវិស័យនាំចេញទើបផុសឡើងថ្មីនានា។ កន្លងមកមានការបង្កើតជាយន្តការស្ថាប័នផ្សេងៗដើម្បីផ្សារភ្ជាប់គោលនយោបាយពាណិជ្ជកម្ម ទៅនឹងទិដ្ឋភាពដ៏ជាក់លាក់នៃបរិបទនៅកម្ពុជា។ វេទិការដ្ឋាភិបាល និងវិស័យឯកជន (G-PSF) ចំនួនពីរដងក្នុងមួយឆ្នាំ មានសារៈសំខាន់បំផុត សម្រាប់ការសន្ទនារវាងរដ្ឋាភិបាល និងវិស័យឯកជននៅថ្នាក់ជាតិ។ រដ្ឋាភិបាល កំពុងពង្រីកការសន្ទនានេះទៅដល់កម្រិតខេត្តទៀត ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា។

បច្ចុប្បន្ន រដ្ឋាភិបាលកំពុងចាត់វិធានការពង្រឹងសមត្ថភាពសភាពាណិជ្ជកម្ម និងសមាគមន៍ផលិតករ ដើម្បីជួយបម្រើវិស័យជំនាញរបស់ខ្លួនកាន់តែប្រសើរ និងធ្វើការកៀងគរទាក់ទាញការគាំទ្រដល់ផ្នែកអាជីវកម្មរបស់ខ្លួន។

ទោះជាបណ្តាញទាក់ទងគ្នា កំពុងរីកចម្រើនឡើងហើយក្តី ប៉ុន្តែការជំរុញអ្នកពាក់ព័ន្ធមកពីវិស័យឯកជន ឲ្យចូលរួមចំណែកយ៉ាងសក្តិសិទ្ធិ នៅតែជាបញ្ហាប្រឈមមួយ។ សហគ្រិនច្រើនតែគិតគូរពីផលចំណេញក្នុងរយៈពេលខ្លី ចំណែកឯពិពិធកម្ម គឺជាយុទ្ធសាស្ត្រមានរយៈពេលវែង។ ដូច្នេះត្រូវតែបង្កើតឲ្យមានជាគោលនយោបាយ ដើម្បីផ្តល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជនឲ្យគាំទ្រពិពិធកម្ម។ នៅក្នុងតំបន់នេះ មានឧទាហរណ៍ជាច្រើន ដែលបង្ហាញពីអន្តរាគមន៍លើកទឹកចិត្តប្រកបដោយជោគជ័យរបស់រដ្ឋាភិបាល ដូចជា នៅជប៉ុន និង កូរ៉េខាងត្បូង ជាដើម។ ការធ្វើវិនិយោគលើការសិក្សាស្រាវជ្រាវពីមេរៀនទាំងនេះ ហើយយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជា អាចផ្តល់ នូវការយល់ដឹងដ៏សំខាន់ផ្នែកគោលនយោបាយ។

ដើម្បីឲ្យគោលនយោបាយពាណិជ្ជកម្ម ជួយការពារផលប្រយោជន៍របស់ជនងាយរងគ្រោះ ត្រូវមានការស្រាវជ្រាវពីឥទ្ធិពលដែលអាចកើតមានពីគោលនយោបាយ ព្រមទាំងការតាមដាន និងវាយតម្លៃលទ្ធផល។ ដើម្បីសម្រេចគោលដៅនេះ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (DTIS) ឆ្នាំ២០០៧ បានកំណត់ឃើញ ១៩វិស័យ ដែលមានសក្តានុពលសម្រាប់ការនាំចេញ និងមានផលប៉ះពាល់វិជ្ជមានដល់ការកាត់

បន្ថយភាពក្រីក្រ។ រដ្ឋាភិបាល ត្រូវបង្កើនសមត្ថភាពនៅក្នុងបណ្តាញស្ថាប័នស្រាវជ្រាវរបស់កម្ពុជា ដើម្បីឲ្យមានការវិភាគស៊ីជម្រៅពីទំនាក់ទំនងរវាងការអភិវឌ្ឍវិស័យនាំចេញ និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព។

ជាលទ្ធផលនៃការស្រាវជ្រាវ និងការប្រឹក្សាយោបល់ជាច្រើននេះ នៅខែកក្កដា ២០១០ សម្តេចនាយករដ្ឋមន្ត្រីបានអនុម័តចេញនូវឯកសារ ស្តីពីការលើកកម្ពស់ផលិតកម្មស្រូវ និងគោលនយោបាយនាំចេញស្រូវអង្ករ ដែលជាកិច្ចប្រឹងប្រែងលើកទីមួយ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនៃវិស័យនាំចេញជាលក្ខណៈឯកជន។ ឯកសារនេះ ក៏ស្ថិតក្នុងក្របខ័ណ្ឌ SWAp ដ៏សំខាន់ និងបានផ្តោតលើការកាត់បន្ថយភាពក្រីក្រផងដែរ។ ឯកសារនេះ អាចប្រើជាគំរូមួយសម្រាប់គោលនយោបាយស្រដៀងៗគ្នា ដែលផ្តោតលើវិស័យដទៃទៀត។

## ការកសាងសមត្ថភាពស្ថាប័នសម្រាប់ពាណិជ្ជកម្ម

ក្របខ័ណ្ឌ SWAp មានគោលដៅកសាងសមត្ថភាពស្ថាប័នជាតិ ដើម្បីអនុវត្តគោលនយោបាយពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព។ ការកសាងសមត្ថភាពស្ថាប័នសំខាន់ណាស់ ព្រោះរដ្ឋាភិបាលទទួលខុសត្រូវក្នុងការសម្របសម្រួល SWAp ហើយវាអាចជួយបង្កើនលទ្ធផលគម្រោងនានា។ គោលដៅចំបងមួយទៀត គឺកែលំអការសម្របសម្រួលក្នុងជួររដ្ឋាភិបាល។ មធ្យោបាយមួយដែល SWAp ចូលរួមចំណែកដល់គោលដៅនេះ គឺការតភ្ជាប់អាទិភាពរបស់ក្រសួងផ្សេងៗ តាមរយៈការតម្រឹមគ្នាជាមួយមូលដ្ឋានគ្រឹះទាំង ៣។ ឧទាហរណ៍ មន្ទីរជំនាញ និងអ្នកពាក់ព័ន្ធផ្សេងទៀត បង្កើតជាសំណើសុំមូលនិធិ "ពីក្រោមឡើងលើ" ទាក់ទិននឹងមូលដ្ឋានគ្រឹះទាំង ៣។

គំនិតផ្តួចផ្តើមជាច្រើនបានផុសឡើង សំដៅបង្កើនសមត្ថភាពស្ថាប័ន ដើម្បីឆ្លើយតបចំពោះតម្រូវការនៃកំណើន និងធ្វើពិពិធកម្មពាណិជ្ជកម្ម។ ឧទាហរណ៍ គម្រោង TRADE របស់ UNDP ផ្តោតលើការកសាងសមត្ថភាពរបស់នាយកដ្ឋានសំខាន់ៗមួយចំនួននៅក្រសួងពាណិជ្ជកម្ម។ តាមរយៈគម្រោង ការជំរុញក្របខ័ណ្ឌសមាហរណកម្មកម្រិត១ គេបានជ្រើសរើសនាយកដ្ឋានសំខាន់ៗមួយចំនួននៅតាមក្រសួងជំនាញ ដែលដើរតួនាទីគន្លឹះក្នុងពាណិជ្ជកម្ម មកកសាងសមត្ថភាពបន្ថែម និងកែលំអការផ្តល់សេវាកម្ម (ឧទាហរណ៍ MAFF MIME CDC និង RSA)។

រដ្ឋាភិបាលកម្ពុជា ឈានមុខគេក្នុងការអនុវត្តក្របខ័ណ្ឌ SWAp ដែលមានន័យថា សមត្ថភាពស្ថាប័នរបស់កម្ពុជាធ្លាប់បានប្រើប្រាស់យ៉ាងពេញបន្ទុកនៅតាមក្រសួង និងស្ថាប័នជាច្រើន។ ការសម្របសម្រួលអន្តរក្រសួងប្រកបដោយប្រសិទ្ធភាពជួបការលំបាក ហើយការសម្របសម្រួលធនធានក្នុងក្របខ័ណ្ឌ SWAp ពាណិជ្ជកម្មទាំងមូល វាកាន់តែស្មុគស្មាញខ្លាំងទៀត។ បញ្ហាសំខាន់មួយ គឺការកាត់បន្ថយការិយាធិបតេយ្យ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវការងារត្រួតស៊ីគ្នា និងការធ្វើឲ្យសាមញ្ញនូវការតម្រូវផ្សេងៗឲ្យពិនិត្យតាមដាន និងរាយការណ៍។

ការដើរតួនាទីនាំមុខគេ ក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ជួយបង្កើនភាពជាម្ចាស់ និងផ្តល់ផលប្រយោជន៍ដល់កម្ពុជាក្នុងរយៈពេលវែង។ ទោះយ៉ាងនេះក្តី បច្ចុប្បន្នកម្ពុជាច្បាស់ជាមិនទាន់មានសមត្ថភាពស្ថាប័នគ្រប់គ្រាន់ ដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាពទេ។ រដ្ឋាភិបាលបានទទួលស្គាល់ថា កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលរៀនសូត្រយ៉ាងមមាញឹក ហើយប្រមើលថា ត្រូវការរយៈពេលពី ៥ ទៅ ១០ឆ្នាំ ដើម្បីអភិវឌ្ឍស្ថាប័នឲ្យបានដល់ស្តង់ដារពិភពលោក។

បញ្ហាចំបងមួយ គឺការសម្របសម្រួល និងការកំណត់ដំណោះស្រាយប្រាកដនិយម សម្រាប់បញ្ហាសមត្ថភាពស្ថាប័ន។ ក្នុងការអនុវត្តជាក់ស្តែង តែងមានការរំពឹងទុកមិនដូចគ្នាទេ ទាក់ទងនឹងល្បឿន និងលក្ខណៈនៃការកសាងសមត្ថភាព។ ករណីនេះក៏ឃើញមានដែរ សូម្បីតែនៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់ដៃគូអភិវឌ្ឍន៍។ ក្រុមបម្រើការនៅក្នុងប្រទេសកម្ពុជា ជាទូទៅគេគិតយល់ពីក្របខ័ណ្ឌពេលវេលា៥-១០ឆ្នាំនេះ ប៉ុន្តែទីស្នាក់ការកណ្តាលរបស់ពួកគេវិញ ច្រើនតែមិនយល់ទេ និងមានការរំពឹងទុកមិនប្រាកដនិយម។ ភាពមិនស៊ីគ្នានេះ ធ្វើឲ្យអន្តរាយដល់ដំណើរការបង្កើត និងអនុវត្តគោលនយោបាយសមស្រប និងមានការសម្របសម្រួលល្អ។ គម្លាតនៃការរំពឹងទុកនេះត្រូវតែកាត់បន្ថយ ព្រោះដើម្បីឲ្យគោលនយោបាយទទួលបានជោគជ័យ ការរំពឹងទុក ត្រូវតែស៊ីគ្នានឹងស្ថានភាពជាក់ស្តែងនៃសមត្ថភាពស្ថាប័ន។

## ការកសាងសមត្ថភាពសម្រាប់វិនិយោគផ្នែកឯកជន

ក្របខ័ណ្ឌគោលនយោបាយ និងបទបញ្ញត្តិអំណោយផលដល់វិនិយោគិន គួបផ្សំជាមួយឧត្តមភាពប្រៀបធៀបជាច្រើន ធ្វើឲ្យវិស័យឯកជន មានភាពកក់ក្តៅចំពោះប្រទេសកម្ពុជា ហើយជឿជាក់កាន់តែខ្លាំងឡើង លើអនាគតសេដ្ឋកិច្ចរបស់កម្ពុជា។ តួយ៉ាង ធនាគារ ANZ រំពឹងថា សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រហែល ៧% ក្នុងឆ្នាំនេះ និងកំណើនពី ៨% ទៅ ១០% ក្នុងបី-បួនឆ្នាំខាងមុខ ពោលគឺមានសុទិដ្ឋិនិយមច្រើនជាងការរំពឹងទុករបស់ IMF។ ដូចគ្នាដែរ ធនាគារពិភពលោក រំពឹងថាវិនិយោគផ្ទាល់ពីបរទេស នឹងកើនយ៉ាងលឿននៅឆ្នាំនេះ ហើយឡើងដល់ ៩៧១លានដុល្លារ នៅឆ្នាំ២០១២ (រូបភាព ២)។

តំបន់សេដ្ឋកិច្ចពិសេស (SEZ) ជាឧទាហរណ៍មួយបង្ហាញពីជោគជ័យនៃក្របខ័ណ្ឌបទបញ្ញត្តិ និងគោលនយោបាយបច្ចុប្បន្នរបស់កម្ពុជា ក្នុងការទាក់ទាញវិនិយោគឯកជន បើសិនឧបសគ្គផ្នែកស្ថាប័នត្រូវបានដោះស្រាយយ៉ាងសមស្រប។ ជាលក្ខណៈគោលនយោបាយ ច្បាប់សម្រាប់ SEZ មានលក្ខណៈស្រដៀងគ្នាច្រើននឹងច្បាប់សម្រាប់ប្រទេសកម្ពុជា ប៉ុន្តែ SEZ មានបុគ្គលិកសកម្មក្នុងការអនុវត្តច្បាប់នេះ និងដោះស្រាយបញ្ហានានានៅពេលវាផុសឡើង ធ្វើឲ្យការអនុវត្តមានល្បឿនលឿនជាង និងងាយស្មានដឹងមុនជាងនៅកន្លែងផ្សេងៗទៀត។

ទំហំវិនិយោគនៅក្នុងតំបន់ SEZ ជាភស្តុតាងបង្ហាញថាដំណើរការអនុវត្តប្រកបដោយតម្លាភាព ទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់វិនិយោគិន។ បញ្ហាប្រឈមនៅពេលនេះ គឺត្រូវរៀនសូត្រពីបទពិសោធន៍ល្អៗនៅតំបន់ SEZ ហើយសំខាន់បំផុតត្រូវចេះច្នៃវាយកមកអនុវត្តលើសេដ្ឋកិច្ចកម្ពុជាជាទូទៅ។

រូបភាព ២៖ វិនិយោគផ្ទាល់ពីបរទេស




ប្រភព៖ ធនាគារពិភពលោក (ការប៉ាន់ស្មានសម្រាប់ឆ្នាំ២០១០-២០១២)

មកទល់សព្វថ្ងៃ ក្របខ័ណ្ឌស្ថាប័នបានកើនសមត្ថភាពច្រើនណាស់ហើយ ក្នុងការជួយសម្រួលវិនិយោគ។ កម្ពុជាមានស្ថាប័នល្អវិសេសមួយចំនួន ដែលបានសម្រេចលទ្ធផលច្រើនណាស់ក្នុងការទាក់ទាញវិនិយោគមកកម្ពុជា គឺមានដូចជា ធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការជ្រោមជ្រែងពីខាងក្រៅ (ដូចជា WTO និង អាស៊ាន ជាដើម) បានជួយបង្កើនគុណភាពស្ថាប័នរបស់កម្ពុជា។ ការតម្រូវផ្សេងៗលើសមាជិកភាព បានដើរតួជាឧបករណ៍ផ្តល់សញ្ញាដាស់អារម្មណ៍រដ្ឋាភិបាល អំពីឧបសគ្គសំខាន់ៗដែលរាំងស្ទះវិនិយោគ ហើយបានជួយរដ្ឋាភិបាលក្នុងការសម្របសម្រួលក្រសួងនានា និងអនុម័តគោលនយោបាយគាំទ្រអាជីវកម្មនៅក្នុងប្រទេសទៀតផង។

ទោះបីមានសញ្ញាគួរឲ្យពេញចិត្តដូចខាងលើក្តី ក៏នៅមានចន្លោះខ្វះខាតមួយចំនួនដែលត្រូវដោះស្រាយ។ បញ្ហាចោទចំបងមួយ គឺអំពើពុករលួយដែលឃើញមានពាសពេញក្នុងស្ថាប័នសំខាន់ៗ ដូចជា ខាងតុលាការជាដើម ទោះបីជារដ្ឋាភិបាលកំពុងប្រឹងប្រែងដោះស្រាយក្តី។

ស្របតាមការរីកចម្រើនពិពិធកម្មសេដ្ឋកិច្ច និងកំណើនទំហំវិនិយោគ ស្ថាប័ននានាត្រូវប្រឈមមុខកាន់តែញឹកញាប់ឡើងនឹងការអនុវត្តគោលនយោបាយដ៏ស្មុគស្មាញ និងការពង្រឹងច្បាប់រឹតតែស្មុគស្មាញ។ ក្របខ័ណ្ឌស្ថាប័នមិនគ្រប់គ្រាន់សម្រាប់អនុវត្តគោលនយោបាយដោយមានតម្លាភាព និងលក្ខណៈងាយស្មានដឹងមុន នឹងរារាំងយ៉ាងខ្លាំងដល់វិនិយោគនាពេលអនាគត។ បញ្ហានេះ ចោទឡើងជាពិសេសចំពោះវិស័យដែលត្រូវការរយៈពេលវែង ដើម្បីទទួលបានផលត្រឡប់វិញ ដូចជា កសិកម្មជាដើម។

បរិយាកាសវិនិយោគអាចកែលំអឡើងបាន តាមរយៈការបង្កើតក្របខ័ណ្ឌស្ថាប័នថ្មីៗ សម្រាប់ដោះស្រាយបញ្ហាជាក់លាក់មួយចំនួនប្រកបដោយតម្លាភាព។ ក្របខ័ណ្ឌថ្មីៗទាំងនេះមានដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយជម្លោះខាងឧស្សាហកម្ម និងគណៈកម្មការសុរិយោដីដោះស្រាយជម្លោះដីធ្លីជាដើម។ ដោយឡែក ក្រុមប្រឹក្សាអាជ្ញាកណ្តាលទំនងទទួលបានជោគជ័យច្រើន ព្រោះមានគេជឿទុកចិត្តកាន់តែធំទូលាយឡើង។ នៅពេលកសាងឡើងបានពេញលេញ ក្របខ័ណ្ឌនេះនឹងក្លាយជាមធ្យោបាយមួយ សម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ហើយផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់មជ្ឈដ្ឋានអាជីវកម្ម។

ក្របខ័ណ្ឌស្ថាប័នថ្មីៗ ដែលផ្តោតលើវិស័យជាក់លាក់នៃការអនុវត្តគោលនយោបាយ មានគុណប្រយោជន៍ជាច្រើន។ ការបង្កើតស្ថាប័នតុលាការឯករាជ្យ ជួយឲ្យវិនិយោគមិនជួបឧបសគ្គនៃកង្វះសមត្ថភាពស្ថាប័នតុលាការ ហើយតុលាការក៏មិនរងសម្ពាធ ដោយសារមានករណីក្តីក្តាំស្មុគស្មាញច្រើនលើសលុបនោះដែរ។ ក្របខ័ណ្ឌស្ថាប័នថ្មីៗ នឹងលើកកម្ពស់បរិយាកាសវិនិយោគសម្រាប់កម្ពុជា ដោយកាត់បន្ថយហានិភ័យ និងភាពមិនច្បាស់លាស់ ជាពិសេសក្នុងចំណោមវិនិយោគិនបរទេស។

បញ្ហាប្រឈមមួយទៀត គឺការកាត់បន្ថយភាពមិនច្បាស់លាស់បណ្តាលមកពីព័ត៌មានមិនគ្រប់គ្រាន់។ បញ្ហានេះពាក់ព័ន្ធជាពិសេសនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារពលកម្ម។ ឧទាហរណ៍ជាក់ស្តែងមួយនៃឧបសគ្គរាំងកំណើនវិនិយោគ គឺថ្លៃអគ្គិសនី។ មែនហើយ ការផ្គត់ផ្គង់អគ្គិសនីកំពុងតែកើនឡើង ប៉ុន្តែគេមិនដឹងច្បាស់ទេថា កំណើននេះនឹងជះឥទ្ធិពលយ៉ាងដូចម្តេចទៅលើថ្លៃអគ្គិសនីនាពេលអនាគត។ ដើម្បីធ្វើវិនិយោគ អ្នកធ្វើជំនួញ តែងត្រូវការចង់ដឹងពីបម្រែបម្រួលថ្លៃអគ្គិសនីក្នុងរយៈពេលពី ៥ ទៅ ១០ឆ្នាំខាងមុខ ហើយរចនាសម្ព័ន្ធទីផ្សារពលកម្ម គេក៏ចង់ដឹងដូចគ្នាដែរ។ ព័ត៌មានប្រភេទនេះ សំខាន់បំផុតសម្រាប់លើកទឹកចិត្តដល់វិនិយោគមានរយៈពេលវែង។

ស្ថិរភាព ជាកត្តាសំខាន់បំផុតសម្រាប់វិនិយោគិនរយៈពេលវែង។ ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ជាចំណុចខ្លាំងមួយរបស់កម្ពុជា។ ដើម្បីរក្សាបាននូវឧត្តមភាពនេះ គឺមានបញ្ហាខ្លះៗដែលត្រូវដោះស្រាយ។ អតិផរណាថ្លៃស្បៀងអាហារ អាចបង្កជាអស្ថិរភាពសង្គម និងប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ។ ការបណ្តេញប្រជាជនចេញពីសហគមន៍ក្នុងតំបន់ទីក្រុងនានា កំពុងក្លាយជាក្តីបារម្ភមួយ ហើយបញ្ហានេះឃើញមានរាយការណ៍ច្រើនណាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ និងតាមរយៈអង្គការអន្តរជាតិនានា។ ការផ្សព្វផ្សាយព័ត៌មានទាំងនេះអាចជះឥទ្ធិពលមិនល្អដល់វិនិយោគទៅថ្ងៃអនាគតនៅកម្ពុជា។


☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh